សហព័ន្ធ ស្រូវ អង្ករ កម្ពុជា
Cambodia Rice Federation

លេខ: ០០៤១/១៥ ស.អ.ក

# លិខិតថ្លែងអំណរគុណ

**ជូនចំពោះ**

**ឯកឧត្តម គង់ វិបុល ប្រតិភូរាជរដ្ឋាភិបាល ទទួលបន្ទុកអគ្គនាយកដ្ឋានពន្ធដារ**

ក្នុងនាមក្រុមប្រឹក្សាភិបាល និងសមាជិកសហព័ន្ធស្រូវអង្ករកម្ពុជាទាំងអស់ ខ្ញុំសូមថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងមន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលបានអនុញ្ញាតឲ្យក្រុមប្រឹក្សាភិបាល និងសមាជិកសហព័ន្ធបានចូលជួបសម្តែងការគួរសម ពិភាក្សាការងារ និងធ្វើបទបង្ហាញពាក់ព័ន្ធនឹងការយកពន្ធលើវិស័យស្រូវអង្ករនៅកម្ពុជា កាលពីថ្ងៃទី២៥ ខែកុម្ភៈ ឆ្នាំ២០១៥ កន្លងទៅថ្មីៗនេះ។

ឆ្លៀតឱកាសនេះ យើងខ្ញុំសូមគោរពនិងកោតសរសើរ នូវកាយវិការដែលយកចិត្តទុកដាក់របស់ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និងមន្ត្រីអគ្គនាយកដ្ឋានពន្ធដារ ក្នុងការចូលរួមស្វែងរកនូវដំណោះស្រាយ លើកទឹកចិត្តវិស័យស្រូវអង្ករ និងជំរុញអនុវត្តនូវរបបពន្ធដោយមានប្រសិទ្ធភាព។ យើងខ្ញុំសង្ឃឹមយ៉ាងជឿជាក់ថា បន្ទាប់ពីកិច្ចប្រជុំនេះ អគ្គនាយកដ្ឋានពន្ធដារនឹងបន្តកិច្ចសហប្រតិបត្តិការយ៉ាងជិតស្និតជាមួយសហព័ន្ធស្រូវអង្ករកម្ពុជា ក្នុងការធ្វើអោយការចុះបញ្ជី និងការបំពេញកាតព្វកិច្ចបង់ពន្ធរបស់រោងម៉ាស៊ីនស្រូវ និងអ្នកប្រកបរបរនៅក្នុងវិស័យស្រូវអង្ករ ប្រកបដោយភាពរលូននិងមានប្រសិទ្ធភាពខ្ពស់។

ក្នុងឱកាសឆ្នាំថ្មីខាងមុខនេះ ខ្ញុំសូមប្រសិទ្ធពរជ័យ និងគោរពជូនពរដល់ ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល និង មន្ត្រីនៃអគ្គនាយកដ្ឋានពន្ធដារទាំងអស់ សូមទទួលបាននូវសុខភាពល្អ ជោគជ័យគ្រប់ភារៈកិច្ច និងសមប្រកបតែពុទ្ធពរទាំង៤ប្រការ គឺ អាយុ វណ្ណៈ សុខៈ ពលៈ កុំបីឃ្លៀងឃ្លាតឡើយ។

សូម **ឯកឧត្តមប្រតិភូរាជរដ្ឋាភិបាល** មេត្តាទទួលនូវការគោរពរាប់អានដ៏ខ្ពង់ខ្ពស់ ពីខ្ញុំបាទ។

រាជធានីភ្នំពេញ ថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៥

**ប្រធានសហព័ន្ធស្រូវអង្ករកម្ពុជា**

**សុខ ពុទ្ធិវុធ**